**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**លេខ :** ០៤៤ ប្រ.ក.ព

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលនៃសម័យប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី
# ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩

នៅព្រឹកថ្ងៃសុក្រ ២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩ វេលាម៉ោង៨និង៣០នាទីព្រឹក នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី មានបើកកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យនិងពិភាក្សាលើ៖

**១-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម។**
**២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ។**
**៣-បញ្ហាផ្សេងៗ៖** សំណើសុំការយល់ព្រមពីគណៈរដ្ឋមន្ត្រី ដើម្បីសុំការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិលើ «កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រកម្ពុជានិងអង្គការហាមឃាត់អាវុធគីមី (OPCW) ស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អង្គការOPCW»។

ក្រោយពីបានស្តាប់របាយការណ៍ និងមតិពិភាក្សាផ្លាស់ប្តូរយោបល់រួចមក អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានសម្រេចអនុម័ត៖

## ១-សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម

សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមត្រូវបានរៀបចំឡើងវិញ ដោយអនុវត្តតាមអនុសាសន៍ទី៩ របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការដាក់ឱ្យអនុវត្តរបបសោធននិវត្តសម្រាប់កម្មករនិយោជិតវិស័យឯកជន និងរបបហានិភ័យការងារសម្រាប់មន្ត្រីសាធារណៈ ឆ្នាំ២០១៩ ដើម្បីធានាបាននូវប្រសិទ្ធភាព និរន្តរភាព និងសង្គតិភាពនៃការអនុវត្តប្រព័ន្ធសន្តិសុខសង្គមមួយស្របតាមបរិបទនៃបណ្តាប្រទេសក្នុងតំបន់និងពិភពលោក។

សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គមនេះមានវិសាលភាពធំទូលាយ ដែលនឹងជំនួសឱ្យច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ដែលជាក្របខណ្ឌគតិយុត្តគោលដំបូងក្នុងការដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារនិងផ្នែកថែទាំសុខភាព។

សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម មានគោលបំណងបង្កើតឱ្យមានរបបសន្តិសុខសង្គមនៃព្រះរាជាណាចក្រកម្ពុជា តាមគោលការណ៍សាមគ្គីធម៌និងសមធម៌សង្គមដែលរួមមាន៥ផ្នែកគឺ ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ សម្រាប់បុគ្គលិកដែលស្ថិតក្នុងវិស័យសាធារណៈ បុគ្គលដែលស្ថិតក្រោមច្បាប់ស្តីពីការងារ គិតរួមទាំងបុគ្គលិកជួរអាកាស នាវិកសមុទ្រ និងអ្នកបម្រើតាមផ្ទះ ព្រមទាំងបុគ្គលស្វ័យនិយោជន៍ ដែលចូលរួមចំណែកក្នុងការលើកកម្ពស់ជីវភាព ភាពថ្លៃថ្នូរ និង ភាពសុខដុមរមនាក្នុងសង្គម។



95

សេចក្តីព្រាងច្បាប់ស្តីពីរបបសន្តិសុខសង្គម ត្រូវបានបែងចែកចេញជា១១ជំពូក រួមមាន៖ ជំពូកទី១ បទប្បញ្ញត្តិទូទៅ ជំពូកទី២ គោលការណ៍ទូទៅនៃរបបសន្តិសុខសង្គម ជំពូកទី៣ ស្ថាប័នមានសមត្ថកិច្ច ជំពូកទី៤ របបសន្តិសុខសង្គមផ្នែកផ្នែកប្រាក់សោធន ជំពូកទី៥ របបសន្តិសុខសង្គមផ្នែកថែទាំសុខភាព ជំពូកទី៦ របបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ជំពូកទី៧ របបសន្តិសុខសង្គមផ្នែកនិកម្មភាពការងារ ជំពូកទី៨ សហវិធាន ជំពូកទី៩ ទោសប្បញ្ញត្តិ ជំពូកទី១០ អន្តរប្បញ្ញត្តិ ជំពូកទី១១ អវសានប្បញ្ញត្តិ និង ឧបសម្ព័ន្ធ។

## ២-សេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ

បន្ទាប់ពីបានរំដោះប្រទេសកម្ពុជាឱ្យរួចផុតពីរបបប្រល័យពូជសាសន៍ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ រដ្ឋាភិបាលនិងប្រជាជនកម្ពុជាបានខិតខំស្តារនិងកសាងប្រទេសឡើងវិញពីបាតដៃទទេឱ្យមានការរីកចម្រើន លើគ្រប់វិស័យ ក្នុងនោះរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ខ្ពស់ផងដែរក្នុងការលើកកម្ពស់ការប្រើប្រាស់ភាសា និងអក្សរខ្មែរដែលជាអត្តសញ្ញាណជាតិប្រកបដោយនិរន្តរភាព។

គោលនយោបាយភាសា ត្រូវបានធ្វើស្ថាប័ននីយកម្មក្នុងបរិបទប្រទេសជាច្រើនក្នុងពិភពលោកក៏ដូចជា ក្នុងតំបន់ប្រមាណជិតបួនទស្សវត្សរ៍មកហើយ ហើយការរៀបចំគោលនយោបាយភាសានីមួយៗនោះធ្វើឱ្យ មានការផ្លាស់ប្តូរជាវិជ្ជមានក្នុងការប្រើភាសារបស់ខ្លួនសម្រាប់ជាមូលដ្ឋានគ្រឹះនៃសុខដុមនីយកម្មសង្គម។

ភាសាខ្មែរនិងអក្សរខ្មែរបានវិវត្តក្នុងប្រវត្តិជ័យរលង់របស់ខ្លួន និងមានការវិវត្តធំៗជាច្រើនលើករហូត ដល់បច្ចុប្បន្ន។ ទន្ទឹមនឹងការវិវត្តនៃសង្គមក្នុងរយៈពេលកន្លងមក ការប្រើភាសាខ្មែរនាពេលបច្ចុប្បន្ននៅមិនទាន់ មានការឯកភាពគ្នាទាំងស្រុងនៅឡើយលើការសរសេរ ការអាន ការកំណត់និយមន័យ ការបង្កើតពាក្យ ការខ្ចីពាក្យ និងក្បួនវេយ្យាករណ៍ខ្មែរជាដើម ដែលជាហេតុនាំឱ្យចោទជាបញ្ហាក្នុងការប្រើភាសាខ្មែរនៅតាម ប្រព័ន្ធផ្សព្វផ្សាយ និងការខ្វះពាក្យប្រើប្រាស់តាមតម្រូវការក្នុងសង្គមផងដែរ។

សេចក្តីព្រាងគោលនយោបាយជាតិស្តីពីភាសាខ្មែរ ត្រូវបានបង្កើតឡើងក្នុងគោលបំណងលើកកម្ពស់ ឧត្តមភាពភាសាជាតិនិងជំរុញឱ្យមានការឯកភាពគ្នាក្នុងការប្រើភាសាជាតិ ដើម្បីធានាបាននូវការអភិរក្ស និងអភិវឌ្ឍភាសាខ្មែរប្រកបដោយភាពសុខដុម តាមរយៈការដាក់ចេញនូវគោលដៅធំៗចំនួន៦ រួមមាន៖ ទី១.បង្កើតយន្តការនិងកំណត់គោលការណ៍ក្នុងការអភិរក្សនិងអភិវឌ្ឍភាសាខ្មែរ ទី២.បង្កើនការប្រើភាសាខ្មែរ ជាភាសាយានដើម្បីទទួលយកចំណេះដឹងនិងជំនាញផ្សេងៗឱ្យបានទូលំទូលាយ ទី៣.ជំរុញនិងលើកកម្ពស់ ការប្រើពាក្យនិងបច្ចេកសព្ទជាភាសាខ្មែរ និងជំរុញការប្រើពាក្យនិងបច្ចេកសព្ទកម្ចីឱ្យស្របតាមគោលការណ៍ ភាសាជាតិ ទី៤.ជំរុញនិងលើកកម្ពស់ការប្រើភាសាខ្មែរឱ្យបានទូលំទូលាយនិងត្រឹមត្រូវ ទី៥.កំណត់និង ត្រួតពិនិត្យឱ្យមានឯកភាពក្នុងការប្រើភាសាខ្មែរ និង ទី៦.ជំរុញនិងលើកកម្ពស់ការស្រាវជ្រាវ ការប្រមូល ការចងក្រង ការថែរក្សា និងការផ្សព្វផ្សាយឯកសារទាក់ទងនឹងភាសាខ្មែរ។

## ៣-បញ្ហាផ្សេងៗ៖

៣.១. អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានអនុម័តបញ្ជូន «កិច្ចព្រមព្រៀងរវាងព្រះរាជាណាចក្រ កម្ពុជានិងអង្គការហាមឃាត់អាវុធគីមី(OPCW) ស្តីពីបុព្វសិទ្ធិនិងអភ័យឯកសិទ្ធិរបស់អង្គការOPCW» ទៅសុំ ការអនុម័តយល់ព្រមពីស្ថាប័ននីតិប្បញ្ញត្តិ។

៣.២. សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងពីភាពវិជ្ជមាន ដែលឯកឧត្តម Michael Richard Pompeo រដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិក បានថ្លែងក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាននៅទីក្រុងបាងកក ប្រទេសថៃ កាលពីថ្ងៃទី១ ខែសីហា ឆ្នាំ២០១៩ កន្លងទៅនេះ ថាឯកឧត្តមស្វាគមន៍ចំពោះការបដិសេធរបស់កម្ពុជាលើព័ត៌មានពាក់ព័ន្ធនឹងវត្តមាន នៃមូលដ្ឋានយោធាចិននៅតំបន់ឈូងសមុទ្រកម្ពុជា ក៏ដូចជាបានកោតសរសើរកម្ពុជាចំពោះការប្តេជ្ញា ខ្លាំងក្លាក្នុងការការពារបូរណភាពដែនដីរបស់ខ្លួន និងបានលើកទឹកចិត្តឱ្យប្រទេសផ្សេងទៀតក្នុងតំបន់ដើរ តាមលំនាំរបស់កម្ពុជា។

៣.៣. សម្តេចតេជោនាយករដ្ឋមន្ត្រី បានបង្ហាញជំហរម៉ឺងម៉ាត់ក្នុងការអនុវត្តអភិក្រមទី៥ “វះកាត់” ដោយបានធ្វើការព្រមានដកហូតបុណ្យសក្តិ ព្រមទាំងបង្កកទ្រព្យសម្បត្តិ ចំពោះមន្ត្រីរាជការនិងកងកម្លាំងប្រដាប់អាវុធទាំងឡាយណាដែលបានប្រើតួនាទីប្រព្រឹត្តអំពើពុករលួយ កិបកេងទ្រព្យសម្បត្តិរដ្ឋ កាប់បំផ្លាញព្រៃឈើ រំលោភយកដីរដ្ឋធ្វើជាទ្រព្យសម្បត្តិផ្ទាល់ខ្លួន និងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមានថែមទៀត។

៣.៤. សម្តេចតេជោនាយករដ្ឋមន្ត្រី បានលើកទឹកចិត្តឱ្យមានការកែច្នៃសំរាមក្នុងស្រុកដើម្បីផលិតជាថាមពលអគ្គិសនីបន្ថែមទៀត ក្នុងការចូលរួមការពារបរិស្ថាន និងដោះស្រាយបញ្ហាសំរាមក៏ដូចជាទីលានចាក់សំរាម ជាពិសេសនៅរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ។ សម្តេចតេជោនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា កម្ពុជាមិនអនុញ្ញាតដាច់ខាតឱ្យមានការនាំចូលសំរាមពីបរទេសដើម្បីកែច្នៃឬក៏ផលិតជាថាមពលអគ្គិសនីនោះទេ។

៣.៥. សម្តេចតេជោនាយករដ្ឋមន្ត្រី បានណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិទាំងអស់ ត្រូវរួមគ្នាបន្តយកចិត្តទុកដាក់ខ្ពស់លើការដោះស្រាយបញ្ហាទឹកជូនប្រជាពលរដ្ឋ ជាពិសេសចំពោះទីកន្លែងមួយចំនួនដែលនៅកំពុងបន្តជួបប្រទះគ្រោះរាំងស្ងួតនៅឡើយ និងត្រូវត្រៀមផ្តល់ស្រូវពូជជូនប្រជាពលរដ្ឋដែលរងការខូចខាតនិងមានការខ្វះខាត។ ទន្ទឹមនឹងនេះ សម្តេចតេជោនាយករដ្ឋមន្ត្រី ក៏បានក្រើនរំលឹកដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលដែនដីពាក់ព័ន្ធទាំងអស់ ជាពិសេសប្រជាពលរដ្ឋផ្ទាល់ ត្រូវបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះការកើនឡើងនៃកម្ពស់ទឹកតាមដងទន្លេនៅរដូវវស្សានេះ ដែលអាចបង្កជាគ្រោះទឹកជំនន់។

៣.៦. សម្តេចតេជោនាយករដ្ឋមន្ត្រី បានផ្តាំសួរសុខទុក្ខដល់មន្ត្រីរាជការគ្រប់ជាន់ថ្នាក់ ជាពិសេសកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលបាននិងកំពុងឈរជើងតាមខ្សែបន្ទាត់ព្រំដែន តាមបណ្តាកោះក្នុងដែនសមុទ្រកម្ពុជា និងប្រចាំការនៅតាមគ្រប់ទីកន្លែង ដែលតែងតែខិតខំថែរក្សាការពារសន្តិភាពនិងបូរណភាពទឹកដីជាតិមាតុភូមិដោយឥតងាករេ។

អង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី បានបិទសម័យប្រជុំនៅវេលាម៉ោង១១និង២៥នាទី។

ថ្ងៃសុក្រ ២កើត ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី២ ខែសីហា ឆ្នាំ២០១៩